

# ការប្រើប្រាស់កៅអីសុវត្ថិភាពកុមារ

## ពាក់ឲ្យបានត្រឹមត្រូវរាល់ពេលធ្វើដំណើរ - ការណែនាំអំពីការរក្សាសុវត្ថិភាពកូនរបស់អ្នក

## សូមពិនិត្យកៅអីរៀងរាល់ថ្ងៃ ដើម្បីធានានូវសុវត្ថិភាព

- ✓ កៅអីមានទំហំត្រឹមត្រូវសម្រាប់កុមារ
- ✓ បានដំឡើងកៅអីត្រឹមត្រូវក្នុងរថយន្ត
- ✓ បានដាក់គន្លឹះខ្សែក្រវ៉ាត់កុមារដោយសុវត្ថិភាព

ប្រហែល៧០ភាគរយនៃកៅអីសុវត្ថិភាព ពុំបានដំឡើងត្រឹមត្រូវឡើយ។ ដើម្បីការពារកូនរបស់អ្នក វាជាការសំខាន់ដែលត្រូវដំឡើងកៅអីរថយន្តរបស់អ្នកឲ្យបានត្រឹមត្រូវ ហើយប្រើវាឱ្យបានត្រឹមត្រូវរាល់ពេលធ្វើដំណើរ។

## កៅអីសុវត្ថិភាពកុមារបែរទៅមុខ និងបែរទៅក្រោយ



**ពាក់ខ្សែចងទប់ការពារឲ្យជាប់ ហើយមិនរមួល**

ទាញសម្រួលបន្ទះខ្សែឲ្យជាប់ដោយកុំឲ្យមានគម្លាតលើសពី២ម្រាមដៃ នៅចន្លោះកូនរបស់អ្នក និងខ្សែចងទប់ការពារ។

**ទប់ដៃឲ្យបានជាប់**

ពិនិត្យមើលថាបន្ទះខ្សែចងទប់ការពារដែលពាក់ទប់ដៃរបស់កូនអ្នក ត្រូវបានពាក់ត្រឹមត្រូវ។

**ដាក់គន្លឹះខ្សែក្រវ៉ាត់**

ពិនិត្យមើលថាខ្សែក្រវ៉ាត់ដែលភ្ជាប់ជាមួយកៅអីសុវត្ថិភាពកុមារ ត្រូវបានដាក់គន្លឹះជាប់ល្អ។

**ឧបករណ៍ភ្ជាប់** ISOFIX

ប្រសិនបើកៅអីរបស់អ្នកបានភ្ជាប់ជាមួយឧបករណ៍ ISOFIX ត្រូវពិនិត្យមើលថាឧបករណ៍ភ្ជាប់នេះ បានដាក់គន្លឹះចំកន្លែងត្រឹមត្រូវ។

**ក្បាលខ្សែសំប៉ែតផ្នែកខាងលើ**

ធានាថាក្បាលខ្សែសំប៉ែតផ្នែកខាងលើ ត្រូវបានភ្ជាប់ទៅនឹងទីតាំងកៅអីសុវត្ថិភាពកុមារត្រឹមត្រូវ។



## កៅអីបន្ទុប

**ពាក់ខ្សែក្រវ៉ាត់ឲ្យជាប់**

ពិនិត្យមើលថាខ្សែក្រវ៉ាត់សុវត្ថិភាពត្រូវបានពាក់ជាប់ ហើយផ្នែកភ្លៅនៃខ្សែក្រវ៉ាត់សុវត្ថិភាពកាត់ផ្នែកលើភ្លៅ និងកាត់លើត្រគាក - មិនមែនផ្នែកពោះទេ។

**សេចក្តីណែនាំអំពីការពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព**

ប្រើសេចក្តីណែនាំអំពីការពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព ដើម្បីដាក់ខ្សែក្រវ៉ាត់សុវត្ថិភាពឲ្យចំត្រូវទីតាំង នៅលើស្មារបស់កូនអ្នក។

**ក្បាលខ្សែសំប៉ែតផ្នែកខាងលើ**

ប្រសិនបើមានក្បាលខ្សែសំប៉ែតផ្នែកខាងលើ ត្រូវធានាថាបានដាក់វាភ្ជាប់ទៅនឹងទីតាំងកៅអីសុវត្ថិភាពកុមារត្រឹមត្រូវ។

## ការពិនិត្យសុវត្ថិភាពប្រចាំខែ

ត្រូវពិនិត្យថា តើកៅអីសុវត្ថិភាពនៅតែមានទំហំត្រឹមត្រូវសម្រាប់កូនលោកអ្នកឬអត់។ ពេលណាស្មារបស់កុមារនៅពីលើស្នាមគំនូសនៃកម្ពស់ស្មាខាងលើ  អាចផ្លាស់ប្តូរកុមារទៅកៅអីសុវត្ថិភាពកុមារ ដែលមានទំហំធំជាងនៅក្នុងប្រភេទដូចគ្នា ឬផ្លាស់ប្តូរទៅប្រភេទកៅអីសុវត្ថិភាពកុមារបន្ទាប់។ ប្រើប្រភេទនីមួយនៃកៅអីសុវត្ថិភាពកុមាររហូតដល់កូនរបស់អ្នកធំពាក់លែងកើត។




## ដើម្បីសុវត្ថិភាព ត្រូវបន្តប្រើប្រាស់កៅអីសុវត្ថិភាព រហូតដល់កូនរបស់អ្នកធំពាក់លែងកើត ទោះជាវាមានអាយុប៉ុន្មានឆ្នាំក៏ដោយ



### កៅអីសុវត្ថិភាពកុមារបែរទៅក្រោយ

ប្រើរន្ធស៊កខ្សែសំប៉ែតចងការពារដែលនៅជិតស្មារបស់កូនអ្នកបំផុត ក៏ប៉ុន្តែមិនមែននៅក្រោមស្មាទេ។

### កៅអីសុវត្ថិភាពកុមារបែរទៅមុខ

ប្រើរន្ធស៊កខ្សែសំប៉ែតចងការពារដែលនៅជិតស្មារបស់កូនអ្នកបំផុត ក៏ប៉ុន្តែកុំឲ្យលើសពី២.៥សង្ទីម៉ែត្រក្រោមស្មា។



### កៅអីបន្ទុប

កែសម្រួលក្បាលកៅអីសុវត្ថិភាពប្រសិនបើស្មារបស់កូនអ្នកនៅពីលើស្នាមគំនូសផ្នែកខាងលើ។

### ខ្សែក្រវ៉ាត់សុវត្ថិភាពសម្រាប់មនុស្សធំ

ខ្សែក្រវ៉ាត់សម្រាប់មនុស្សធំដែលមានបំពាក់ខ្សែឆៀងកាត់ភ្លៅ បានផលិតឡើងសម្រាប់មនុស្សដែលមានកម្ពស់១៤៥សង្ទីម៉ែត្រអប្បបរមា។



- ✓ ស្វែងរកកន្លែងបំពាក់កៅអីសុវត្ថិភាព **RACV** ដែលនៅជិតអ្នកបំផុត **racv.com.au/childrestraints**
- ✓ ពិនិត្យសុវត្ថិភាព និងភាពងាយស្រួលនៃវាយតម្លៃការប្រើប្រាស់ **childcarseats.com.au**
- ✓ អនុវត្តតាមការណែនាំរបស់ក្រុមហ៊ុនជានិច្ចនៅពេលដំឡើង និងប្រើប្រាស់កៅអីសុវត្ថិភាព

### ការប្រឹក្សាដោយអ្នកជំនាញអំពីកៅអីសុវត្ថិភាព

racv.com.au/childrestraints
1800 134 126

vicroads.vic.gov.au
13 11 71

kidsafevic.com.au
9036 2306

VICTORIA State Government — Education and Training

RACV

vicroads

Kidsafe — CHILD ACCIDENT PREVENTION FOUNDATION OF AUSTRALIA — Making a Safer World for Kids for over 30 years

TAC TRANSPORT ACCIDENT COMMISSION

បានធ្វើទាន់បច្ចុប្បន្នភាពនៅខែធ្នូ ឆ្នាំ២០១៦